# សិទ្ធិមនុស្ស

## Human Rights

- ប្រវត្តិខ្លះៗនៃសិទ្ធិមនុស្ស :
- តើមនុស្សមានសិទ្ធិ ពីពេល ណាមក ?

  ហើយសិទ្ធិនោះ មានលក្ខណៈយ៉ាងដូចម្ដេច ?

-យោង សេចក្ដីប្រកាសឯករាជ្យឆ្នាំ១៧៧៦( ប្រទេសអាមេរិច)

តាមធម្មជាតិ មនុស្សគ្រប់រូបគឺមានសិទ្ធិសេរីភាព និងឯករាជ្យដោយស្មើភាពគ្នា ហើយមានសិទ្ធិផ្ទាល់ខ្លួនខ្លះ... ដូចជាសិទ្ធិមានភាពសប្បាយរីករាយនៅក្នុងជីវិត និងមានសេរីភាព ដោយមានលទ្ធភាពទទួល និងកាន់កាប់កម្មសិទ្ធិលើទ្រព្យសម្បត្តិ និងការស្វែងរក និងការទទួលបាននូវសុភមង្គល និង សុវត្ថភាព ។

-យោង សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ ឆ្នាំ១៧៨៩

( ប្រទេសបារាំង)

**មនុស្សគ្រប់រូបកើតមក មានសិទ្ធិសេរីភាព និងសមភាព**

ចំលើយៈ បើយោងតាមសេចក្តីប្រកាសទាំងពីរខាងលើមានន័យថា :

សិទ្ធិមនុស្ស ចាប់មានតាំងពីធម្មជាតិរបស់មនុស្សដែលកើត ចេញពី

ផ្ទៃម្តាយមកម្លេះ ។ ហើយមានលក្ខណៈស្មើៗគ្នា ( សមភាព) ។

- **ចរិកលក្ខណៈនៃសិទ្ធិមនុស្ស ៖**

-ជាធម្មជាតិរបស់បុគ្គលម្នាក់ៗ

-សកល

-មិនអាចបំបែកបាន

-មិនអាចលក់ ឬផ្ទេរបាន

- **ប៉ុន្តែការអនុវត្តន៍ជាក់ស្តែងក្នុងសង្គម ថាតើពិតដូចទ្រឹស្តីដែរឬទេ ? ហេតុអ្វី ?**

- **១៩១៤-១៩១៨** (សង្គ្រាមលោកលើកទី១)
- **សង្គមប្រជាជាតិ**
- **១៩៣៩-១៩៤៥** (សង្គ្រាមលោកលើកទី២)

ដែល បង្ករឱ្យមនុស្ស ជាង៥០លាន នាក់ត្រូវស្លាប់ ។

- កែប្រែសង្គមប្រជាជាតិ អោយក្លាយជាអង្គការសហប្រជាជាតិ ហើយអង្គការនេះបានធ្វើសេចក្តីថ្លែងការជាសកលស្តីពីសិទ្ធិ មនុស្ស ដែលសេចក្តីថ្លែងការកានេះត្រូវបានអនុម័តជាឯកច្ឆន្ទ ដោយមហា សន្និបាតអង្គការសហប្រជាជាតិ និង ប្រកាស់ទទួលស្គាល់យ៉ាង ឧឡារិកតាមសេចក្តីសំរេចលេខ ២១៧៤ នៅ ថ្ងៃទី **១០ ខែ ធ្នូ ឆ្នាំ ១៩៤៨**

ប៉ុន្តែសេចក្តីប្រថ្លៃងការណ៍នេះវាគ្រាន់តែជាប្រភពគំនិតនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិតែប៉ុណ្ណោះ វាមិនមែនជាឯកសារកតិយុត្តិនោះទេ ។

ប៉ុន្តែគោលការណ៍នៃសេចក្តីថ្លៃងការណ៍នេះ ត្រូវបានប្រែសំរួលទៅជាកំលាំងគតិយុត្តិ ក្នុងទំរង់កតិកាសញ្ញាអន្តរជាតិពីរគឺ :

១-កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ ពលរដ្ឋ និង នយោបាយ

២-កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គម និងវប្បធម៌

# កតិកាសញ្ញា ស្ដីពី សិទ្ធិពលរដ្ឋ និងសិទ្ធិ នយោបាយ

- **ឆ្នាំ១៩៦៦ :** កតិកាសញ្ញាស្ដីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (**ICCPR**)

កតិកាសញ្ញានេះចូលជាធរមាននៅ**ឆ្នាំ១៩៧៦** ហើយព្រះរាជាណាចក្រកម្ពុជាបានឱ្យសច្ចាបន័ **នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩២** ។



កតិកាសញ្ញាអន្តរជាតិស្ដីអំពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

**ដោយហេតុថា** កតិកាសញ្ញាអន្តរជាតិស្ដីអំពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ បានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ ចុះថ្ងៃ ១៦ ធ្នូ ឆ្នាំ ១៩៦៦ ។

**ដូច្នេះ ក្នុងពេលនេះ** យើងខ្ញុំដែលជាសមាជិកនៃឧត្ដមក្រុមប្រឹក្សាជាតិកម្ពុជា ប្រកាសថា ឧត្ដមក្រុមប្រឹក្សាជាតិ, ដោយបានទទួលស្គាល់កតិកាសញ្ញាខាងលើនេះ នឹងចូលជាសមាជិក ហើយទទួលរ៉ាប់រងយ៉ាងស្មោះស្ម័គ្រ ដើម្បីបំពេញភារកិច្ច និង អនុវត្តតាមបដិញ្ញា (ខ) ដែលមានចែងនៅក្នុងនោះ ។

**ដើម្បីជាបន្ទាល់សាក្សី** យើងខ្ញុំបានចុះហត្ថលេខាលើឯកសារនៃការចូលជា សមាជិកនេះ នៅមហាប្រាសាទខេមរិន្ទ ភ្នំពេញ កម្ពុជា នៅថ្ងៃទី...២០... ខែ..មេសា.....ឆ្នាំ ១៩៩២

- **ICCPR រួមបញ្ចូលសិទ្ធិមួយចំនួនគឺ :** (មើលមាត្រា ៦ ដល់ ២៧)

-សិទ្ធិរស់រានមានជីវិត

-សិទ្ធិរួចផុតពីទណ្ឌកម្ម ឬទាសភាព

-សិទ្ធិមានសេរីភាព និងសន្តិសុខ

-សិទ្ធិសេរីភាពក្នុងការធ្វើដំណើរហើរ បង្កើតសមាគម ខាងសាសនា និងក្នុងការបញ្ចេញមតិ យោបល់

-សិទ្ធិស្មើគ្នាចំពោះមុខច្បាប់

-សិទ្ធិស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ និង

-សិទ្ធិក្នុងការគោរពតាមទំនៀមទំលាប់វប្បធម៌ខ្លួន

# យន្តការត្រួតពិនិត្យៈ

-បង្កើតគណៈកម្មការសិទ្ធិមនុស្សដើម្បីពិនិត្យ តាមដាន （ផ្នែកទី៤ និង មាត្រា៤០）

-ទទួល និងពិនិត្យរាល់បណ្តឹងរបស់ប្រទេសហត្ថលេខីផ្សេងៗ （ម៤១）

- ទទួល និងពិនិត្យរាល់បណ្តឹងរបស់បុគ្គល ដែលជឿថាសិទ្ធិរបស់ គេត្រូវបានរំលោភ （តាមពិធីសារ）

# កតិកាសញ្ញាស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌

- **ឆ្នាំ១៩៦៦ :** កតិកាសញ្ញាស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ (**CESCR**)

កតិកាសញ្ញានេះចូលជាធរមាននៅ**ឆ្នាំ១៩៧៦** ហើយព្រះរាជាណាចក្រកម្ពុជាបានឱ្យសច្ចាបន័ **នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩២** ។


កម្ពុជា

**កតិកាសញ្ញាអន្តរជាតិអំពីសិទ្ធិក្នុង**
**វិស័យសេដ្ឋកិច្ច សង្គម និង វប្បធម៌**

**ដោយហេតុថា** កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិក្នុងវិស័យសេដ្ឋកិច្ច សង្គម និង វប្បធម៌ បានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ ចុះថ្ងៃ ១៦ ធ្នូ ឆ្នាំ ១៩៦៦ ។

**ដូច្នេះ ក្នុងពេលនេះ** យើងខ្ញុំដែលជាសមាជិកនៃឧត្តមក្រុមប្រឹក្សាជាតិកម្ពុជា ប្រកាសថា ឧត្តមក្រុមប្រឹក្សាជាតិ, ដោយបានទទួលស្គាល់កតិកាសញ្ញាខាងលើនេះ, នឹងចូលជាសមាជិក ហើយទទួលកំប់រងយ៉ាងស្មោះស្ម័គ្រ ដើម្បីបំពេញភារកិច្ច និង អនុវត្តតាមបដិញ្ញា (ខ) ដែលមានចែងនៅក្នុងនោះ ។

**ដើម្បីជាបន្ទាល់សាក្សី** យើងបានចុះហត្ថលេខាលើឯកសារនៃការចូលជា សមាជិកនៅមហាប្រាសាទនេមរិន្ទ ភ្នំពេញ កម្ពុជា នៅថ្ងៃទី...២០... ខែ..មេសា......ឆ្នាំ ១៩៩២

- **ICESCR រួមបញ្ចូលនូវ :**

-សិទ្ធិការងារ មានស្ថានភាពការងារត្រឹមត្រូវ និងល្អប្រសើរ

-សិទ្ធិបង្កើត និងចូលរួមក្នុងសហជីព

-សិទ្ធិមានជីវិតគ្រួសារ

-សិទ្ធិមានកំរិតជីវភាពរស់នៅគ្រប់គ្រាន់

-សិទ្ធិមានកំរិតសុខភាពខ្ពស់បំផុតដែលអាចធ្វើទៅបាន

-សិទ្ធិទទួលការអប់រំ

-សិទ្ធិចូលរួមក្នុងសកម្មភាពវប្បធម៌

**<u>យន្តការត្រួតពិនិត្យ:</u>** មានតែមួយគត់គឺ

-រដ្ឋភាគីនីមួយៗត្រូវមានកាតាព្វកិច្ចរាយការណ៍ ។ គឺធានាធ្វើយ៉ាងណាអោយរដ្ឋភាគីត្រួតពិនិត្យអោយបានជាប់ជាប្រចាំពីសភាពការណ៍ដែលទាក់ទិននិងការគោរពសិទ្ធិនីមួយៗ និងវិសាលភាព នៃសិទ្ធិទាំងនោះថា តើពលរដ្ឋគ្រប់រូបទទួលបានរឺទេ នៅក្នុងប្រទេសរបស់ពួកគេ ឬនៅក្រោមយុត្តាធិការរបស់ពួកគេ ។ (មាត្រា១៦)

មិនតែប៉ុណ្ណោះក៏មានអនុសញ្ញាជាច្រើនទៀតដែលបានបង្កើតឡើងដូចជា :

## ព្រំដែននៃសិទ្ធ

ជាធម្មជាតិសិទ្ធិគ្មានព្រំដែលទេ តែនៅពេលដែលមនុស្សចូលមករស់នៅក្នុងសង្គម មនុស្សត្រូវតែប្រគល់សិទ្ធិមួយចំនួនឱ្យទៅសង្គមដើម្បីគ្រប់គ្រង ដូច្នេះការកំរិតមួយចំនួននោះហើយជាព្រំដែននៃសិទ្ធិ ។

-សិទ្ធិ និងសិទ្ធិរបស់អ្នកដទៃ: មនុស្សម្នាក់ៗអាចធ្វើអ្វីៗបានទាំងអស់ដរាបណាមិនប៉ះពាល់ដល់សិទ្ធិអ្នកដ៏ទៃ

-ច្បាប់: មនុស្សម្នាក់ៗអាចធ្វើអ្វីៗបានទាំងអស់ដរាបណាច្បាប់មិនហាមឃាត់

-ប្រពៃណី ទំនាមទំលៀបសង្គម